ទូរស័ព្ទ: 023 888 161-162
អ៊ីមែល:advertising@phnompenhpost.com
វេបសាយ.postkhmer.com/ប៉ុស្តិ៍យានយន្ត

# ប៉ុស្តិ៍យានយន្ត

ទូរស័ព្ទ: 023 888 161-162
អ៊ីមែល:advertising@phnompenhpost.com
វេបសាយ.postkhmer.com/ប៉ុស្តិ៍យានយន្ត

ថ្ងៃសុក្រ ទី៦ ខែមីនា ឆ្នាំ២០២០

WWW.POSTKHMER.COM/ប៉ុស្តិ៍យានយន្ត

## ផ្លាស់ប្តូរទិសដៅ



# MERCEDES V-CLASS ជារថយន្តដ៏ប្រណី




ភាពបត់បែននៃរថយន្ត Mercedes V-Class កំពុងបង្ហាញនូវភាពទាក់ទាញយ៉ាងខ្លាំងដល់ អតិថិជនកម្ពុជា ឲ្យបង្វែរពីរថយន្តប្រភេទ SUV ជារថយន្តដែលទទួលបានការគាំទ្រខ្លាំង ។

លោក យុន ចាន់ថា នាយកគ្រប់គ្រងផ្នែកលក់ និងទីផ្សារនៃក្រុមហ៊ុន ស្តារ អូតូ (កម្ពុជា) Star Auto (Cambodia) ដែលជាក្រុមហ៊ុនទទួលបានសិទ្ធិនាំចូលនិងចែកចាយរថយន្ត Mercedes-Benz ផ្តាច់មុខនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានលើកឡើងអំពីមុខងារច្រើនបែបនៃរថយន្ត ដ៏ទំនើបមួយនេះ។

លោក ចាន់ថា មានប្រសាសន៍ថា៖ «រថយន្ត V-Class អាចប្រើប្រាស់បានសម្រាប់គ្រប់សកម្មភាពប្រចាំថ្ងៃ សម្រាប់ការធ្វើដំណើរទៅតាមបណ្តាខេត្តនៅចុងសប្តាហ៍ សម្រាប់ដំណើរបំពេញកិច្ចការធុរកិច្ច និងសម្រាប់ដឹកជញ្ជូនភ្ញៀវលក្ខណ: VIPs ពីព្រលានយន្តហោះមកកាន់សណ្ឋាគាររបស់ពួកគេជាដើម»។

រថយន្តដ៏ប្រណីតនេះបំពាក់ដោយកៅអីដ៏ធំទូលាយ មានផាសុកភាពផ្ទៃខាងក្នុងមានភ្លើងដ៏ស្រទន់ស្រស់ស្អាត មានប្រអប់ត្រជាក់ មានប្រព័ន្ធសម្លេងព័ទ្ធជុំវិញ មានប្រព័ន្ធត្រួតពិនិត្យអាកាសធាតុ អមដោយរចនាបថដ៏ស្រស់ឆើតឆាយ ដែលធ្វើឲ្យអ្នកដំណើរមានអារម្មណ៍ស្រស់ស្រាយពោពេញទៅដោយភាពជឿជាក់។

ប្រជាប្រិយភាពនៃរថយន្តប្រភេទ ៦,៧និង៨កៅអី (ផ្អែកតាមការជ្រើសរើសរបស់អតិថិជន)រថយន្តប្រភេទនេះមានសារៈសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជាពីព្រោះវាអាចប្រើប្រាស់សម្រាប់សកម្មភាពច្រើនយ៉ាង។

«អតិថិជនអាចជ្រើសរើសយករថយន្ត V-Class ដ៏ទំនើបនេះ សម្រាប់ធ្វើដំណើរជាមួយក្រុមគ្រួសារប្រកបដោយទំនុកចិត្ត។ នៅក្នុងគ្រួសារខ្មែរមួយចំនួន ស្វាមីអាចមានរថយន្តមួយ ភរិយាអាចមានរថយន្តមួយ ចំណែកឯកូនប្រុសស្រីរបស់ពួកគេអាចមានរថយន្តផ្ទាល់ខ្លួនផ្សេងទៀត»។

លោកចាន់ថាថ្លែងថា៖«ជាមួយរថយន្ត V-Class គ្រួសារទាំងមូលអាចធ្វើដំណើររួមជាមួយគ្នាបាន ដើម្បីពង្រឹងទំនាក់ទំនងរបស់ពួកគេ ក៏ដូចជាអាចសន្សំថវិការបានផងដែរ មិនថាការធ្វើដំណើរកម្សាន្តចុងសប្តាហ៍ ការប្រើប្រាស់សម្រាប់សកម្មភាពប្រចាំថ្ងៃ ឬឱកាសពិសេសណាមួយនោះទេ»។

សំណាញ់ប៉ាណានៃរថយន្ត V-Class រំលេចនូវភាពស្រស់សង្ហាចំពោះការបើកបរនៅគ្រប់ទីកន្លែងនៅកម្ពុជា ខណ:រថយន្តម៉ាក Mercedes-Benz MPV បំពាក់នូវរន្ធបញ្ចេញខ្យល់ថ្មីសម្រាប់រូបរាងបែបស្ព័រ។

«រថយន្តប្រភេទ SUV មានប្រវត្តិយូរយារមកហើយនៅក្នុងប្រទេសកម្ពុជាសូម្បីនៅ[ក្រោយជម្លោះ] នាដើមទសវត្សទី៩០ ហើយដោយសារតែកាលនោះ ស្ថានភាពផ្លូវនៅកម្ពុជាមិនសូវល្អ បានធ្វើឲ្យប្រជាជនកម្ពុជាជាច្រើន ចង់ប្រើប្រាស់រថយន្តប្រភេទ SUV។ ប៉ុន្តែបច្ចុប្បន្នស្ថានភាពផ្លូវនៅក្នុងប្រទេសកម្ពុជាកាន់តែល្អប្រសើរ សូម្បីតែផ្លូវចេញពីទីក្រុងភ្នំពេញទៅតាមបណ្តាខេត្តផ្សេងៗ ដូច្នេះប្រជាជនក៏ចាប់ផ្តើមទិញរថយន្តម៉ាកផ្សេង»។ ពេលនេះពួកគេទិញរថយន្ត V-Class ពីព្រោះវាជារថយន្តដែលមានមុខងារច្រើនយ៉ាង ជាពិសេសអាចដឹកមនុស្សបានលើសពី៥នាក់»។

«ជាមួយនឹងការណែនាំរថយន្ត V-Class កាលពី៥ឆ្នាំមុន យើងបានបង្ហាញនូវវត្តមានដ៏ទាន់សម័យនិងប្រកបដោយថាមពលនៃរថយន្តទំហំធំ XXL [extra long version] ។ ដូច្នេះយើងណែនាំដល់ក្រុមគ្រួសារអ្នកចូលចិត្តធ្វើដំណើរបែបផ្សងព្រេងកម្សាន្ត និងដំណើលក្ខណ:ធុរកិច្ច ចាប់តាំងពីតំបន់អឺរ៉ុបរហូតដល់តំបន់អាស៊ី។ ហើយចាប់តាំងពីដាក់លក់មក រថយន្ត V-Class ត្រូវបានលក់អស់ចំនួន ២០៩,០០០ គ្រឿង នៃក្រុមរថយន្ត Mercedes-Benz។

លោក Wilfried Porth នាយកផ្នែកទំនាក់ទំនងការងារនៅក្រុមហ៊ុន Mercedes-Benz Vans ថ្លែងថា៖« ចាប់តាំងពីដើមឆ្នាំ២០២០មក យើងនឹងនៅតែបន្តរឿងជោគជ័យនេះ។ ជាមួយការធ្វើឲ្យកាន់តែទំនើប ដោយយើងបង្កើនការពង្រឹងថាមពលនៃរថយន្ត MPV តាមទិសដៅរបស់យើង»។

រថយន្ត V-Class មានតម្លៃប្រមាណ ១៣១,០០០ដុល្លារ ហើយលោកចាន់ថាបញ្ជាក់ថា ប៉ុន្តែវាមានតម្លៃ៥ម៉ឺនដុល្លារតិចជាងគូប្រកួតប្រជែងរបស់ខ្លួននៅក្នុងថ្នាក់ MPV ប្រណីត ខណ:រថយន្ត V-Class MPVs បើទិញពីទីផ្សារខាងក្រៅនឹងមានតម្លៃថ្លៃជាងនេះ។

លោកចាន់ថាបន្តថា៖«ក្រុមហ៊ុន ស្តារ អូតូ គឺផ្តល់ជូននូវតម្លៃសមរម្យ ពីព្រោះមានការគាំទ្រយ៉ាងខ្លាំងពីក្រុមហ៊ុន Mercedes ជាមួយនឹងតម្លៃពិសេសពីរោងចក្រដើម្បីផ្តល់ជូនប្រជាជនកម្ពុជានូវឱកាសក្លាយជាម្ចាស់រថយន្តដ៏ពិសេសនេះ»។

ចំណុចលេចធ្លោមួយចំនួនទៀតមានដូចជា ផ្នែកខាងមុខដ៏ស្រស់សង្ហា បំពាក់ដោយម៉ាស៊ីន ម៉ាស៊ូត ៤ ស៊ីឡាំង OM 654 ម៉ូឌែល V250



# តដែលអាចប្រើប្រាស់បានគ្រប់ឱកាស

កម្លាំង 211hp ជាមួយនឹងប្រព័ន្ធសុវត្ថិភាពនិងប្រព័ន្ធជំនួយទំនើបចុងក្រោយបំផុត។ រថយន្ត V-Class ទទួលបានចំណាត់ថ្នាក់ផ្កាយ៥ ពេញលេញបន្ទាប់ពីការធ្វើតេស្តដោយស្តង់ដា Euro NCAP។

រថយន្ត V-Class មកពីក្រុមហ៊ុន AMG កំពុងក្លាយជារថយន្តដែលលក់ដាច់បំផុតរបស់ក្រុមហ៊ុន ស្តារ អូតូ ដោយសាតែវាជារថយន្តប្រណីតមានសុវត្ថិភាពខ្ពស់ រូបរាងដ៏ស្រស់សង្ហា និងពោពេញដោយថាមពល។

លោកចាន់ថាបន្ថែមថា៖«នៅពេលអ្នកទិញរថយន្ត Mercedes ពីក្រុមហ៊ុន ស្តារ អូតូ នោះអ្នកនឹងទទួលបានឡានដ៏ប្រណីត ជាមួយនឹងតម្លៃថោកជាងគូប្រជែងរបស់យើង ហើយសូម្បីតែទិញពីទីផ្សារខាងក្រៅ។ រថយន្តដែលទិញពីក្រុមហ៊ុន ស្តារ អូតូ ត្រូវបានធានាថាជារថយន្តMercedes ល្អពិតប្រាកដ។ រថយន្ត V-Class គឺជារថយន្តដ៏សាកសមបំផុតសម្រាប់ក្រុមគ្រួសារនិងសម្រាប់ការប្រើប្រាស់លក្ខណៈអាជីវកម្ម»៕ ■









# ការរំពឹងទុកដ៏អស្ចារ្យ




កាលពីអតីតកាល វាអាចជារឿងពិបាកសម្រាប់អ្នកទិញរថយន្តនៅកម្ពុជាក្នុងការជ្រើសរើសរថយន្តរបស់ចិន ជំនួសឲ្យរថយន្តជប៉ុននិងរថយន្តមកពីអឺរ៉ុប ប៉ុន្តែបច្ចុប្បន្ននេះវាមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

អគ្គនាយកក្រុមហ៊ុន Worldwide Motors (WMC) ដែលជាក្រុមហ៊ុនចែកចាយរថយន្ត Great Wall នៅកម្ពុជាបានថ្លែងថាវាជាពេលវេលាដ៏រំភើបសម្រាប់ឧស្សាហកម្មយានយន្តរបស់ចិននៅកម្ពុជា។

លោក Peang Mann អគ្គនាយកក្រុមហ៊ុន WMC ថ្លែងថាការអភិវឌ្ឍន៍ថ្មីៗ កំពុងត្រួសត្រាយផ្លូវសម្រាប់ការកើនឡើងនូវវត្តមានរថយន្តចិននៅលើដងផ្លូវក្នុងប្រទេសកម្ពុជា។

លោកបញ្ជាក់ថាការផ្លាស់ប្តូរការយល់ឃើញ ក្នុងចំណោមប្រជាជនកម្ពុជាទៅលើក្រុមហ៊ុនផលិតរថយន្តចិន គួបផ្សំនឹងតម្លៃប្រកួតប្រជែង និងសេវាកម្មបន្ទាប់ពីការលក់ធ្វើឱ្យមានវត្តមានរថយន្តមកពីក្រុមហ៊ុនយក្សអាស៊ីមួយនេះកើនឡើង។

លោក Mann បន្តថា៖«ទស្សនៈអវិជ្ជមានចម្បងលើកឡើងថារថយន្តចិនមានតម្លៃទាប ដូច្នេះគេគិតថាវាមានគុណភាពទាបដែរ។ ប៉ុន្តែទោះជាយ៉ាងណាប្រជាជនចាប់ផ្តើមដឹងថាគុណភាពរថយន្តចិនគឺល្អមិនចាញ់រថយន្តផ្សេងទៀតនៅ លើទីផ្សារនោះទេ»។

ជាមួយនឹងតម្រូវការរថយន្តចិនកំពុងកើនឡើង ក្រុមហ៊ុន WMC គ្រោងនឹងបើករោងចក្រតម្លើងរថយន្តថ្មីមួយទំហំពី៣៣ទៅ៥០ ហិកតា នៅខេត្តព្រៃវែងជិតព្រំដែនវៀតណាមក្នុងឆ្នាំនេះ ដោយមានជំនួយបច្ចេកទេសពីក្រុមហ៊ុនរថយន្ត Great Wall ដើម្បីធានាថាគ្រប់រថយន្តរបស់ខ្លួនទាំងអស់ មានគុណភាពខ្ពស់បំផុតមុនពេលទៅដល់ដៃអតិថិជន។

លោក Mann បញ្ជាក់ថា៖«រោងចក្រនេះមានសមត្ថភាពតម្លើងរថយន្តបានចំនួន៥ម៉ឺនគ្រឿងក្នុងមួយឆ្នាំ។ ហើយយើងសង្ឃឹមថានៅក្នុងរយៈពេលពីរឬបីឆ្នាំដំបូង យើងអាចតម្លើងរថយន្តបានចន្លោះពី៥០០ទៅ១០០០គ្រឿងក្នុង១ឆ្នាំ ប៉ុន្តែចំនួននេះនឹងកើនឡើងខណៈវិនិយោគិនចូលមកកាន់តែច្រើន»។

លើសពីនេះទៀត ក្រុមហ៊ុនរថយន្ត Great Wall ទិញរោងចក្ររបស់ក្រុមហ៊ុន General Motors នៅប្រទេសថៃ ដើម្បីពង្រីកទីផ្សារទៅក្នុងទីផ្សារអាស៊ានដែលរួមមានទាំងប្រទេសមីយ៉ាន់ម៉ា វៀតណាម និងប្រទេសឡាវ និងបង្កើនចំណែកទីផ្សារនៅក្នុងបណ្តាប្រទេសដែលខ្លួនដំណើរការរួចហើយ រួមទាំងប្រទេសកម្ពុជាជាមួយប្រទេសម៉ាឡេស៊ីនិងប្រទេសឥណ្ឌូនេស៊ី។

ក្រុមហ៊ុន WMC លក់រថយន្តចិនច្រើនម៉ូឌែលដូចជារថយន្តម៉ាក Great Wall រថយន្ត ភីអាប់ រថយន្តប្រភេទ SUV រាប់ចាប់ពីម៉ាក Haval, Zotye Huanghai, Traum និង FAW ក៏ដូចជារថយន្តមីនីវែន BAW ជាដើម ដែលចាប់ផ្តើមប្រតិបត្តិការចាប់តាំងពីឆ្នាំ២០១៣មកម្លេះ។

ចំពោះតម្លៃវិញមានចាប់ពី ២០,៧០០ដុល្លារ សម្រាប់រថយន្ត Great Wall Voleex C30 និង 45,000 ទៅ ៦៨,០០០ដុល្លារ សម្រាប់រថយន្ត Haval H6 រហូតដល់ ៧៣,០០០ ដុល្លារ សម្រាប់ រថយន្ត ប្រភេទ Haval H9 SUV។ ចំពោះរថយន្ត H9 គឺជារថយន្តធំទូលាយដ៏ទំនើប មាន៧កៅអី នឹងមានតម្លៃសមរម្យ។

ជាមួយនឹងការយល់ដឹងយ៉ាងឆាប់រហ័សនៃគុណភាពដ៏ខ្ពស់ ទើបក្រុមហ៊ុន WMC បានមើលឃើញការលក់រថយន្តចិនកើនឡើងចំនួន៦០ភាគរយកាលពីឆ្នាំមុន ធៀបទៅនឹងឆ្នាំ ២០១៨ ពោលគឺកើនឡើងពី៣០០ទៅ៥០០គ្រឿង។

លោក Mann បានប្តេជ្ញាចិត្តថានឹងជួយប្រជាជនកម្ពុជាឱ្យមានឡានថ្មីផ្ទាល់ខ្លួនហើយលោកបាននិយាយថាការទិញរថយន្តរបស់លោកក៏មានការបង់មុនត្រឹមតែ១៥ទៅ២០ភាគរយនៃតម្លៃរថយន្តនៅក្នុងប្រទេសកម្ពុជា និងមានការផ្តល់សេវាប្រចាំឆ្នាំដោយឥតគិតថ្លៃសម្រាប់អំឡុងពេលបង់ប្រាក់ និងមានការធានារយៈពេលពី៥ទៅ៧ឆ្នាំ។

លោកបានស្វះស្វែងឲ្យមានការជួយពីធនាគារ នៅក្នុងគោលដៅនេះ ដើម្បីផ្តល់ជម្រើសឥណទានកាន់តែច្រើនដល់ទាំងអ្នកទិញនិងអ្នកចែកចាយ ហើយបានអញ្ជើញវិនិយោគិនឲ្យមកកាន់តែច្រើនបន្ថែមទៀត។

លោក Mann ថ្លែងថាការកសាងគុណភាពរថយន្តចិនគឺវាបានឆ្លុះបញ្ចាំងលើកត្តាសុវត្ថិភាព។

«ម៉ាក Haval និងម៉ាកដ៏ទៃទៀតបានទទួលចំណាត់ថ្នាក់សុវត្ថិភាពខ្ពស់បំផុតលំដាប់ផ្កាយ៥ ពីកម្មវិធីវាយតម្លៃសុវត្ថិភាពរថយន្ត ANCAP [Australian New Car Assessment Program] ។

លោកមានប្រសាសន៍ថា៖«ការកសាងគុណភាពនៃរថយន្តចិនរបស់យើងយ៉ាងហោចណាស់គឺដូចគ្នានឹងរថយន្តមកពីក្រុមហ៊ុនផលិតរថយន្តជប៉ុន កូរ៉េ អាមេរិក ឬអាឡឺម៉ង់ ដោយភាគច្រើននៃរថយន្តទាំងនេះគឺផលិតនៅក្នុងប្រទេសចិន»។

ពិតណាស់ ការយល់ឃើញអំពីគុណភាពនៃរថយន្តចិនបានផ្លាស់ប្តូរអស់មួយរយៈពេលមកហើយ។

លោក Robin Page អនុប្រធានជាន់ខ្ពស់ផ្នែករចនាម៉ូឌែលនៅក្រុមហ៊ុនរថយន្ត Volvo បានឲ្យដឹងថាបើងាកត្រឡប់ទៅមើលឆ្នាំ២០១៨វិញ គឺថាគុណភាពនៃការផលិតរថយន្តចិនកើនឡើងគួរឲ្យកត់សម្គាល់ បន្ទាប់ពីក្រុមហ៊ុនផលិតរថយន្តស៊ុយអ៊ែតបានជ្រើសរើសការផលិតរថយន្តនៅក្នុងប្រទេសចិន។

លោក Page ថ្លែងប្រាប់គេហទំព័ររថយន្ត Go Auto របស់អូស្ត្រាលីថា៖« អ្វីដែលយើងរកឃើញគឺថាគុណ-ភាពនៃរថយន្តនៅក្នុងប្រទេសចិនទាំងនោះគឺពិតជាល្អប្រសើរជាងនៅអឺរ៉ុបទៅទៀត។ គ្រប់គ្នាព្រួយបារម្ភអំពីគុណភាពប៉ុន្តែនៅពេលដែលចិនចាប់ផ្តើម នោះគុណភាពខ្ពស់ជាងនៅអឺរ៉ុបទៀត»។ លោក Mann មានទំនុកចិត្តថារថយន្តដែលត្រូវបានលក់ដោយក្រុមហ៊ុន WMC គឺអាចប្រកួតប្រជែងមួយរថយន្តដ៏ទៃទៀតបាន។

លោកបន្ថែមថា៖«ប្រជាជនយល់ដឹងកាន់តែច្រើនថារថយន្តចិនមានភាពទាក់ទាញកម្រិតណា ទាក់ទងនឹងការរចនា លក្ខណៈពិសេស ក៏ដូចជាគុណភាព។ សាកល្បងប្រើប្រាស់រថយន្តចិននោះលោកអ្នកនឹងមើលឃើញដោយខ្លួនឯងថាវាល្អកម្រិតប៉ុណ្ណា»៕ ■



